# ព្រឹត្តិបត្រព័ត៌មាន

## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាប (ធី.អេស.អេស.ឌី)

*ផ្តល់ថវិកាអនុវត្តដោយៈ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា*

គម្រោងទន្លេសាប ធី.អេស.អេស.ឌី៖ ជួយកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ប្រមាណជា ៦៣ម៉ឺនគ្រួសារ ក្នុង១៩៦ឃុំ ២៨ស្រុក ក្នុងខេត្ត បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និង ត្បូងឃ្មុំ តាមរយៈ (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដល់ផលិតភាពកសិកម្ម (២)ការបង្កើនសមត្ថភាពបច្ចេកទេសរបស់កសិករខ្នាតតូច (៣) ការផលិត-ផ្គត់ផ្គង់ពូជដំណាំមានគុណភាព និង (៤) ការផ្តល់ព័ត៌មានដល់កសិករ។

### មាតិកាសម្រាប់ត្រីមាសទី ២ ឆ្នាំ ២០១៦


១. ពីកសិករបង្ហាញត្រសក់ចំណារទៅជាកសិករដាំត្រសក់បែបអាជីវកម្ម
២. សហគមន៍ផលិតពូជស្រូវលក់ជូនកសិករមានការរីកលូតលាស់ (sic)


## ១. ពីកសិករបង្ហាញត្រសក់ចំណារទៅជាកសិករដាំត្រសក់បែបអាជីវកម្ម



ស្រុកស្ទឹងត្រង់៖ នៅភូមិដីក្រហម ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ប្រជាកសិករនិយមដាំបន្លែជាយូរមកហើយ។ ដំណាំត្រសក់ចំណារគឺជា ដំណាំមួយដែលកសិករនិយមដាំផងដែរ ដោយសារដំណាំត្រសក់ចំណារ ងាយស្រួលដាំជាងដំណាំផ្សេងៗ មិនសូវពិបាកក្នុងការមើលថែទាំ ហើយដើមទុនក៏មិនសូវចំណាយច្រើនដែរ។ ក្នុងការដាំត្រសក់ត្រូវតែ ឧស្សាហ៍ព្យាយាម តាមដានសង្កេតជាប្រចាំ ធ្វើយ៉ាងណាឱ្យដំណាំមានសុខភាពល្អដើម្បី ឱ្យទទួលបានផលតាមការរំពឹងទុក។ លោក យ៉ន កេត វ័យ ៤៨ឆ្នាំ ប្រពន្ធ គិត គីមអេង អាយុ ៤៦ឆ្នាំ មានកូន៣នាក់ ស្រី១ ប្រុស២ នៅក្នុងបន្ទុក។ កសិករ យ៉ន កេត ត្រូវបានគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជ្រើសរើសឱ្យធ្វើជាកសិករបង្ហាញដំណាំត្រសក់ចំណារនៅឆ្នាំ២០១៤ នៅលើផ្ទៃដី៣អា។ ការប្រមូលផលលើផ្ទៃដី៣អានេះ បានចំនួន២តោន កន្លះ។ ដោយមើលឃើញការខំប្រឹងប្រែង និងភាពជោគជ័យរបស់ កសិករ យ៉ន កេត គម្រោងបានបន្តជ្រើសរើសឱ្យអនុវត្តកសិកម្មចម្រុះ ដោយមានការគាំទ្រពីគម្រោងក្រោមកិច្ចសហការណ៍ជាមួយ មន្ទីរកសិកម្មខេត្តកំពង់ចាម។ ថ្មីៗនេះ គាត់ក៏បានចូលជាសមាជិកក្រុមកែលម្អរជីវភាពផងដែរ។



កសិករ យ៉ន កេត បានទទួលការបណ្តុះបណ្តាលពីគម្រោងតាមរយៈមន្ទីរកសិកម្មខេត្តកំពង់ចាម អំពីរបៀបដាំត្រសក់ចំណារ ការភ្ជួរដីដាក់ហាលសម្លាប់មេរោគ របៀបធ្វើថ្នាល ការគ្របចង់ផ្លាស្ទីក ការធ្វើដីកំប៉ុសគោក របៀបដាក់ប្រព័ន្ធទឹកទ្រីប ការបណ្តុះកូន និងការថែទាំជាដើម។ ក្រោយពីបានទទួលចំណេះដឹង និងបទពិសោធន៍ពីដំណាំត្រសក់ចំណារ កសិករ យ៉ន កេត ក៏បានឆ្លៀតពេលបង្រៀនដល់កសិករក្រុមកែលម្អរជីវភាពចំនួន៣ថ្ងៃផងដែរ។

ដោយមើលឃើញពីផលចំណេញពីដំណាំត្រសក់ចំណារ កសិករ យ៉ន កេត បានពង្រីកការដាំដុះបន្ថែមពី៣អា ដល់ ៣០អា ដោយបានខ្ចីលុយបង្វិលបន្ថែមពីក្រុមកែលម្អរជីវភាព។ ក្នុងការធ្វើចំការត្រសក់នេះ កសិករ យ៉ន កេត មិនមានដីផ្ទាល់ខ្លួនទេគឺ គាត់បានសុំខ្ចីដីពីបងប្អូនកសិករក្រុមកែលម្អរជីវភាពដែលមានដីទំនេរមិនទាន់ធ្វើកសិកម្ម។ ដំណាំត្រសក់សចំណាររបស់គាត់បានទទួលផលចំណេញគួរសមក្នុងរដូវនេះ។ កសិករ យ៉ន កេត និយាយថា "ការដាំត្រសក់លើផ្ទៃដី៣០អា ខ្ញុំទទួលបានទិន្នផល ១៦តោន កន្លះ និងលក់បានប្រាក់១៦លាន កន្លះ។"

បច្ចុប្បន្ននេះ កសិករ យ៉ន កេត បានប្រែក្លាយពីការដាំត្រសក់ចំណារបង្ហាញទៅជា ការដាំត្រសក់បែបអាជីវកម្ម។ ការដាំត្រសក់លើផ្ទៃដី៣០អា បានចំណាយដើមទុន ៤លានរៀល និងលក់បានប្រាក់ ១៦លាន។ លោក យ៉ន កេត និយាយដោយទឹកមុខញញឹមថា "ការធ្វើអាជីវកម្មត្រសក់បានចំណេញច្រើនគួរសមដែរ ខ្ញុំបានយកលុយចំណេញមកពង្រីកមុខរបរត្រសក់ឱ្យបានច្រើន។" រីឯការរកទីផ្សារលក់ត្រសក់វិញក៏មិនពិបាកដែរ នៅពេលប្រមូលផលត្រសក់ម្តងៗ តែងតែមានឈ្មួញធំៗមកទិញដល់កន្លែង។ កសិករ យ៉ន កេត បាននិយាយថា "ផ្សារទំនើបក៏ធ្លាប់បានបញ្ជាទិញផងដែរ ប៉ុន្តែគាត់នៅមិនទាន់សម្រេចចិត្តចុះកិច្ចសន្យានៅឡើយ ដោយខ្លាចផលិតមិនគ្រប់លក់ឱ្យគេ។"

អាជីវកម្មត្រសក់ចំណាររបស់កសិករ យ៉ន កេត មានការរីកចំរើនទៅមុខ ដែលធ្វើឱ្យជីវភាពរបស់គាត់ធូរធារមួយកម្រិត។ រាល់ការចំណាយលើការផ្គត់ផ្គង់ជីវភាពគ្រួសារ កូនទៅរៀនសូត្រគឺ បានមកពីអាជីវកម្មត្រសក់នេះ។ កសិករ យ៉ន កេត និយាយដោយសប្បាយរីករាយថា "ខ្ញុំចំណេញប្រាក់ច្រើនពីត្រសក់ គ្រួសារមិនខ្វះខាតទៀតទេ បានហូបគ្រប់គ្រាន់។"

## ២. សហគមន៍ផលិតពូជស្រូវលក់ជូនកសិករមានការរីកចម្រើន

ស្រុកបន្ទាយស្រីៈ សហគមន៍អភិវឌ្ឍន៍កសិកម្មក្តីខាងលិចជោគជ័យ ស្ថិតនៅភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី មានចំងាយប្រហែល ៤២គីឡូម៉ែត្រ ពីទីរួមខេត្តសៀមរាប។ ពូជស្រូវសុទ្ធពាណិជ្ជកម្ម ត្រូវបានផលិតដោយសហគមន៍អភិវឌ្ឍន៍កសិកម្មសម្រាប់លក់ជូន ស្ថានីយ៍កសិកម្មទឹកវិលក្នុងខេត្តសៀមរាប កសិករក្នុងស្រុក និងសមាជិកក្រុមកែលម្អជីវភាព។

ក្រុមកសិករផលិតពូជក្នុងក្រមខណ្ឌគោលដៅគម្រោងទាំងអស់បានរំពឹងថា នឹងផលិតពូជសុទ្ធពាណិជ្ជកម្ម មានគុណភាពល្អ ឱ្យបានយ៉ាងហោចណាស់ ៩០០តោន ក្នុងឆ្នាំនេះ សម្រាប់លក់ដល់ ក្រុមកែលម្អរជីវភាព និងអ្នកមានចំណាប់អារម្មណ៍ទិញស្រូវពូជ។ វាត្រូវបានគេប៉ាន់ប្រមាណថា សមាជិកក្រុមកែលម្អរជីវភាពនឹងទិញរហូតដល់ទៅ ៤០តោន នៃពូជស្រូវសុទ្ធពាណិជ្ជកម្មដែលផលិតឡើងដោយក្រុមកសិករផលិតពូជ។



លោក យាប់ វណ្ណៈ ប្រធានសហគមន៍អភិវឌ្ឍន៍កសិកម្មក្តីខាងលិចជោគជ័យបាននិយាយថា "សហគមន៍អភិវឌ្ឍន៍កសិកម្មបានផ្តួចផ្តើមដោយមន្ទីរកសិកម្មស្រុក និងបានចុះបញ្ជីជាផ្លូវការនៅខែកញ្ញា ឆ្នាំ២០១៣។" បច្ចុប្បន្ននេះ សហគមន៍មានសមាជិកចំនួន ៣៣នាក់ ស្ត្រី១១នាក់។ ដោយមានរចនាសម្ព័ន្ធគ្រប់គ្រងល្អ និងមានទុនបង្វិលច្រើន ដែលធ្វើឱ្យផលិតកម្មមានភាពជោគជ័យ និង អាចដំណើរការដោយខ្លួនឯងបាន។ សហគមន៍



អភិវឌ្ឍន៍កសិកម្មមានសហាជីពដាក់ភាគហ៊ុនរហូតដល់ ៩៣នាក់ និងមានភាគហ៊ុន ២៦៥ហ៊ុន ព្រមទាំងមានទុនសរុប ៧.៣២៥.០០០ រៀល។

សហគមន៍មានផ្ទៃដីផលិតពូជស្រូវ១៥ហិចតា នៅឆ្នាំ២០១៤ បានកើនដល់២០ហិចតា នៅឆ្នាំ២០១៥ ផែនការឆ្នាំ២០១៦ គ្រោងផលិតលើផ្ទៃដី ២០ហិចតា។ លោក យាប់ វណ្ណៈ បានឱ្យដឹងថា "ការផលិតនៅឆ្នាំ២០១៤ បាន១៧តោន ឆ្នាំ២០១៥ ផលិតបាន ៩៤តោន និងលក់ដាច់ទាំងអស់។"

លោក សេង ប៊ុនថា ប្រធានក្រុមកសិកម្មស្រុកបន្ទាយស្រី បានឱ្យដឹងថា "ការផលិតស្រូវពូជចំណេញជាងស្រូវធម្មតា។ ស្រូវចំណីលក់បានមួយគីឡូ ពី៨០០រៀល ទៅ ៩០០រៀល ប៉ុន្តែស្រូវពូជលក់បានពី ២.០០០រៀល ដល់ ២.២០០រៀល ដូចនេះ កសិករភាគច្រើនបង្វែរពីផលិតស្រូវចំណីមកផលិតស្រូវពូជវិញ។" លោក សេង ប៊ុនថា បានបន្ថែមថា សហគមន៍អាចដំណើរការទៅបានដោយសារក្រុមនេះមានដើមទុនច្រើនពីអ្នកភាគហ៊ុន។

លោក ហ៊ូ ប៊ុនយ៉េត ទីប្រឹក្សាផ្សព្វផ្សាយកសិកម្មបានឱ្យដឹងថា ការផ្តួចផ្តើមឱ្យមានសហគមន៍អភិវឌ្ឍន៍កសិកម្មគឺ គម្រោងកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានផ្តល់ម៉ាស៊ីនបូមទឹក១ ម៉ាស៊ីនដេរមាត់១ ជញ្ជីង តង់ ការ៉ុង ១.០០០ និងម៉ាស៊ីនវាស់សំណើម១ ព្រមទាំងការគាំទ្របច្ចេកទេស។

លោក យាប់ វណ្ណៈ និងក្រុមកសិករផលិតពូជ សប្បាយរីករាយនឹងមើលឃើញក្រុមមានភាពរីកចំរើន និងបានប្តេជ្ញាបន្តដំណើរការសហគមន៍ឱ្យកាន់តែដំណើរការល្អថែមទៀត។

## ៣. ប្រជាកសិករទូទាំងឃុំស្វាសបានប្រើប្រាស់ទឹកនារដូវប្រាំង

ឃុំស្វាភាស៖ កាលដើមឡើយនៅឃុំស្វាភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មានត្រពាំងមួយតែងតែរីងស្ងួតនៅរដូវប្រាំង។ ឥឡូវនេះ ត្រពាំងតូចបានស្តារឡើងវិញ សម្រាប់ស្តុកទឹកប្រើប្រាស់នៅរដូវប្រាំង។ ការស្តារត្រពាំងនៅឃុំស្វាភាស បានប្រើពេល៦ខែ និងបានបញ្ចប់គម្រោងស្តាររួចរាល់ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥។ គោលបំណងចម្បងក្នុងការស្តារត្រពាំងគឺ សម្រាប់ផ្គត់ផ្គង់ដល់គ្រួសារកសិករចំនួន ៩១៩គ្រួសារ ដែលមានប្រជាជនសរុបចំនួន ១៦៥០នាក់ ព្រមទាំងស្ត្រី ៣៣០នាក់ផងដែរ។

ការខ្វះខាតទឹកប្រើប្រាស់នៅរដូវប្រាំង ជាបញ្ហាលំបាកដល់ប្រជាកសិករក្នុងទូទាំងឃុំស្វាភាស។ លោក ម៉ម ចំរើន វ័យ ៤៥ ឆ្នាំ ជាកសិកររស់នៅក្នុងភូមិ ដែលបានអាស្រ័យផលពីត្រពាំងនេះ បាននិយាយថា "កាលពីនៅជាត្រពាំងតូច គឺពិបាករកទឹកប្រើប្រាស់ និងរកទឹកឱ្យគោផឹកណាស់ ដោយសារភាពរាំងស្ងួតនារដូវប្រាំង។" លោក ចំរើន និយាយបន្តថា "ទឹកក្នុងត្រពាំងឥឡូវនេះ មិនរីងក្នុងរដូវប្រាំងដូចមុនទេ វាអាចប្រើប្រាស់ក្នុងភូមិ និងប្រើប្រាស់ឆ្លងដល់ភូមិផ្សេងទៀតផង ដោយសារនៅរដូវប្រាំងគ្រប់កន្លែងមិនមានទឹកទេ សូម្បីតែអណ្តូងក៏មិនចេញទឹកដែរ។"

លោក ឌៀក រិទ្ធី ទីប្រឹក្សាវិស្វកម្មបានប្រាប់អោយដឹងថា "គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបបានជីកត្រពាំងក្នុងឃុំស្វាភាស ដែលមានទំហំ ៦០ម៉ែត្រ គុណនិង ៦០ម៉ែត្រ និងមានជំរៅ៤ម៉ែត្រ។ ក្រោយពេលស្តាររួចត្រពាំងនេះ អាចស្រោចស្រពបានផ្ទៃដី២៥ហិចតា។" មុនការស្តារត្រពាំងគម្រោងក៏បានធ្វើការសិក្សាលើការធានាសុវត្ថិភាពអភិវឌ្ឍន៍ គឺបានការសិក្សារពីបរិស្ថាន និងសង្គមផងដែរ ដោយធ្វើយ៉ាងណាចៀសវាងផលប៉ះពាល់ដែលអាចកើតមានឡើង។ ប្រជាកសិករមានសាមគ្គីភាពល្អណាស់ គាត់បានមូលមតិគ្នាធ្វើឱ្យដំណើរនៃការស្តារត្រពាំង នៅក្នុងឃុំប្រព្រឹត្តិទៅយ៉ាងរលូន ដោយមិនមានបញ្ហាកើតឡើងទេ ប្រជាជនថែមទាំងជួយសម្របសម្រួលផងដែរ។



អ្នកទទួលផលក្នុងភូមិ មានភាពសប្បាយរីករាយជាខ្លាំង ពេលមានទឹកប្រើប្រាស់គ្រប់គ្រាន់ គាត់អាចស្រោចដំណាំបាន ហើយទឹកក្នុងត្រពាំងអាចឱ្យគោផឹកផងដែរ។ កសិករ លឿង កុសល មានវ័យប្រហែល ៦០ឆ្នាំ ជាប្រធានក្រុមកែលម្អជីវភាពបាននិយាយថា "ត្រពាំងនេះ មានប្រយោជន៍ណាស់ពេលរាំងស្ងួតបានត្រពាំងហ្នឹងហើយ។ វាអាចជួយប្រជាជនក្នុងភូមិ និងសត្វពាហនៈរបស់អ្នកភូមិមិនងាប់ទេ" ។

លោក សាញ់ ចាន់ឡឿន ជំនួយការភូមិ និយាយថា ដើម្បីអោយមានទឹកប្រើប្រាស់ និងថែទាំត្រពាំងឱ្យបានគង់វង្សយូរអង្វែង មេភូមិបានជួយការពារ និងណែនាំដល់ប្រជាជនក្នុងភូមិ និងអ្នកមកប្រើប្រាស់មកពីភូមិផ្សេង កុំឱ្យចោលសម្រាមចូលក្នុងត្រពាំង និងកុំឱ្យនាំគោចូលត្រពាំងដែលបណ្តាលអោយខូចខាតទឹក។

## ៤. ការចិញ្ចឹមមាន់ និងដាំសណ្តែកគួរអាចកែប្រែជីវភាព

លោកស្រី ជួន អាន អាយុ៣៨ឆ្នាំ មានកូនចំនួន៣នាក់ មានទីលំ នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ជាអនុប្រធានក្រុមកែលម្អជីវភាព ដែលមានសមាជិកសរុបចំនួន២៥នាក់ ស្រី៥នាក់។ មុនចូលក្រុមកែលម្អជីវភាព គាត់ជាកសិករម្នាក់ មានជីវភាពដុនដាប និងមានមុខរបរចម្បងគឺ ធ្វើស្រែលើផ្ទៃដីកន្លះហិចតា និងដាំដំណាំបន្ទាប់បន្សំ។ បន្ទាប់ពីបានចូលក្នុងក្រុមកែលម្អជីវភាពកាលពីខែកក្កដា ឆ្នាំ២០១៤ មកដល់ពេលនេះ គាត់ទទួលប្រាក់កម្ចី ចំនួន ៧២០.០០០រៀល ពីក្រុមទុនបង្វិលក្រុមដំណាក់កាលទី១ និងទី២។ គាត់បានបែងចែកជាពីរ សម្រាប់ចិញ្ចឹមមាន់ និងដាំបន្លែវិលជុំលើដីទំហំ ២០ម៉ែត្រគុណ៣០ម៉ែត្រ រួមមានត្រសក់ទ្រើង ឆៃថាវ និង សណ្តែកកួរជាដើម។ គាត់បានទិញមាន់ចំនួន២០ក្បាល ក្នុងនោះមានមេពូជចំនួន៥ក្បាល ធ្វើរោងមាន់១ និងទិញចំណីសម្រាប់លាយជាមួយចំណីមាន់ដូចជា កន្ទក់ ចុងអង្ករសម្រាប់បំប៉នមាន់។ គាត់បានទទួលបច្ចេកទេសពីមន្ត្រីកសិកម្មក្រុង ជាពិសេសពីមន្ត្រីផ្សព្វផ្សាយសង្កាត់។



ឆ្លងកាត់ការអនុវត្តជាក់ស្តែងដែលគម្រោងបានគាំទ្រលោកស្រី ជួន អាន កាន់តែមានបទពិសោធន៍ និងជំនឿទុកចិត្តលើការចិញ្ចឹមមាន់ ការដាំត្រសក់ទ្រើង និងការដាំសណ្តែកគួរជាដើម ។ លទ្ធផលជាក់ស្តែង លោកស្រី ជួន អាន បានលក់មាន់បានជាប្រចាំ ហើយទទួលបានប្រាក់កម្រៃសមរម្យ ដើម្បីទិញសម្ភារៈសិក្សាឱ្យកូនរៀន ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងទុកពង្រីកការចញ្ចឹមមាន់ដោយទិញមេពូជបន្ថែមទៀត។

រីឯដំណាំសណ្តែកកួរវិញ គាត់ប្រមូលផលសរុបបានចំនួន១៨០គីឡូ ក្នុង១ថ្ងៃប្រមូលផលបានពី១២គីឡូ ទៅ១៥គីឡូ លក់បានចំនួន២២ម៉ឺនរៀល និងត្រៀមពង្រីកផ្ទៃដី ១០ម៉ែត្រគុណ២០ម៉ែត្រលើផ្ទៃដីចាស់។ ដោយមានការគាំទ្រទាំងថវិកា និងបច្ចេកទេសពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប លោកស្រីបានមានប្រសាសន៍ថា "ខ្ញុំមានជំនឿយ៉ាងមុតមាំថា ខ្ញុំអាចកែប្រែជីវភាពគ្រួសារខ្ញុំបានប្រសើរជាងមុន ស្របគ្នានឹងការខិតខំប្រឹងប្រែង ការតាំងចិត្តចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ និងការដាំសណ្តែកកួរ ត្រសក់ទ្រើង" ។

តាមរយៈប្រាក់ចំណេញដែលគាត់ទទួលបានពីការលក់មាន់ និងដំណាំរួមផ្សំ គឺពិតជាបានរួម ចំណែកយ៉ាងខ្លាំង ក្នុងសេដ្ឋកិច្ចគ្រួសារ ធ្វើឱ្យជីវភាពគាត់កាន់តែមានភាពប្រសើឡើង។ អាស្រ័យលើភាពជោគជ័យ នៃការចិញ្ចឹមមាន់ និងបន្លែវិលជុំរបស់លោកស្រី ជួន អាន ក្នុងភូមិអញ្ចាញបានទាក់ទាញសមាជិកក្រុមកែលម្អរជីភាពទាំង២៥នាក់ ឱ្យចាប់អារម្មណ៍ងាកមកចិញ្ចឹមមាន់ និងបន្លែវិលជុំទាំងអស់គ្នា។

